# គណបក្ស សិទ្ធិមនុស្ស

**HUMAN RIGHTS PARTY**

បំរើ ការពារ កសាង


លេខ.០០១៧/១០.....គ.ស.ម

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០

## សេចក្តីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** សូមសម្តែងនូវការកោតសសើរ និងអបអរសាទរដ៏ស្មោះស្ម័គ្រ ចំពោះអង្គការ**ខុមហ្វ្រែល** ដែលបានខិតខំប្រឹងប្រែងធ្វើការ អង្កេតស្រាវជ្រាវការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ ហើយរៀបចំសិក្ខាសាលាផ្សព្វផ្សាយនូវរបាយការណ៍ដ៏មានសារប្រយោជន៍នេះ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ។ របាយការណ៍នេះបង្ហាញច្បាស់នូវការយកចិត្តទុកដាក់របស់អ្នកតំណាងរាស្ត្រចំពោះប្រជាពលរដ្ឋខ្មែរជាម្ចាស់ឆ្នោត ដែលបានផ្តល់សេចក្តីទុកចិត្តរបស់ពួកគាត់ចំពោះអ្នកតំណាងរាស្ត្រទាំងនោះ ។

ទន្ទឹមនេះគណបក្សសិទ្ធិមនុស្សដែលបានទទួលសម្លេង គាំទ្រពីពលរដ្ឋខ្មែរជិត៤០ម៉ឺនសម្លេង និងមានអ្នកតំណាងរាស្ត្រ៣រូបបានចុះមូលដ្ឋានជួបប្រជាពលរដ្ឋទូទាំងប្រទេស និងចូលរួមសិក្ខាសាលាវេទិកាសម្តែងមតិដែលរៀបចំដោយអង្គការជាតិ និងអន្តរជាតិសរុបចំនួន២០១លើក ។ ក្នុងចំនួន២០១លើកនេះ ឯកឧត្តម **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សបានចុះមូលដ្ឋានចំនួន១២៦លើក ឯកឧត្តម **យ៉ែម បុញ្ញឫទ្ធិ** ចំនួន៣៤លើក និងឯកឧត្តម **អ៊ូ ច័ន្ទឫទ្ធិ** ចំនួន៤១លើក ។ បើប្រៀបធៀបទៅនឹងគណបក្សដែលទទួលបានសម្លេងគាំទ្រនៅក្នុងសភាជាតិទាំងអស់ គណបក្សសិទ្ធិមនុស្សបានចុះជួបប្រជាពលរដ្ឋម្ចាស់ឆ្នោតជាច្រើនលើក ពុំដូចសម្តីបុគ្គលខ្លះបាននិយាយនោះទេ ។ ការនិយាយថាមានតែគណបក្សកាន់អំណាចទេ ដែលបានចុះជួបប្រជាពលរដ្ឋជាម្ចាស់នោះ គឺជាពាក្យកុហកដែលគណបក្សសិទ្ធិមនុស្សពុំអាចទទួលយកបាន ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង

ទូរស័ព្ទលេខ ៖ ០១៦ ៤៣៥ ១០៦


Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info